# ជំពូក៦

## ការអង្កេតរកដាន

ទំរាំតែបាយរួច ម៉ោងជិតបីរសៀលទៅហើយ ។ អ្នកស៊ើបការណ៍ទាំងពីរនាក់ គ្មានបានសម្រាក់កាយសោះ គ្រាន់តែលុបមុខបន្តិចបន្តួច ហើយក៏ស្លៀកពាក់រៀបចំខ្លួន ។

– លោកចៅហ្វាយស្រុក (សាវ៍ណ្យមានវាចាទៅវង្គិរិទ្ធិ) នៅក្នុងសាលាលោកមានអង្គុលីលេខទេ ?

– បាទ ! មានមួយដែរ ។

– បើងចឹងខ្ញុំសុំទៅមើលម៉ាស៊ីននោះមួយភ្លែត ដើម្បីចាប់ផ្ដើមការ ។

– បាទមានអ្វីអញ្ជើញមកថ្មើរនេះ ប្រហែលលោកស្មៀនសាលាមកដល់ហើយ ។

លុះមន្ត្រីទាំងនេះចូលទៅដល់ក្នុងសាលាស្រុកហើយលោកចៅហ្វាយបង្គាប់ឱ្យលោកស្មៀនសាលាចាក់សោបើកគម្របអង្គុលីលេខដែលនៅជិតតុលោកស្មៀនសាលានោះ ។

– អុះ ! មានចាក់សោផង ? (លោកអធិការមើលចំលោក ស្មៀន) លោកកាន់កូនសោម៉ាស៊ីននេះតាំងពីកាលណាមក ?

– បាទតាំងពីខ្ញុំបាទផ្លាស់មករវៀងនេះ គិតទៅជាងពីរឆ្នាំហើយ (ស្មៀនឆ្លើយ) ។



– លោកប្រើប្រាស់តែម្នាក់ឯងទេឬ ។ ក៏មានគេឯទៀតប្រើដែរ?

– ទានមានដែរ អ្នកណាគេចង់វាយមកវាយទៅក្នុងពេលធ្វើការ ។

– ចុះបើមានគេក្រៅពីលោកមកវាយ តើលោកជ្រាបថាគេវាយអ្វីខ្លះទេ ?

– ទានដឹងទាំងអស់ ព្រោះខ្ញុំបាទនៅជិតនេះតែងដើរចុះឡើងតាមនេះ ហើយតែងក្រឡេកមើលមិនដែលខានទេ ។

– ចុះការអ្វីសម្ងាត់ ឬរាយការណ៍លោកចៅហ្វាយអ្នកណាជាអ្នកវាយទៅ ?

– ខ្ញុំបាទនេះហើយជាអ្នកវាយ ព្រោះគេឯទៀតពុំសូវចេះរៀបចំដាក់ឱ្យត្រូវខ្នាតធ្លាប់ គ្រាន់តែវាយដឹកាបញ្ជូនបន្តិចបន្តួចប៉ុណ្ណោះ ។

– អ្នកណាខ្លះចេះវាយម៉ាស៊ីន ?

– ទានស្មៀនឯទៀត សុទ្ធតែចេះទាំងអស់ មិនចេះតែលោកយោក្ស័ត្រប៉ុណ្ណោះ ។

លោកអធិការទាញក្រដាសមួយសន្លឹកដែលនៅលើតុជិតនោះមកស៊កក្នុងម៉ាស៊ីនសរសេរនេះ ហើយចុចផ្សំឱ្យបានជាពីរបីប្រយោគរួចដកក្រដាសនោះមកពិនិត្យមើលជាមួយនឹងលោកកុម្មីស្ស៊ែរ ។

– ម៉ាស៊ីនហ្នឹងហើយ (លោកកុម្មីស្ស៊ែរខ្សឹបនឹងត្រចៀកលោកអធិការ) ។

– ហ្នឹងច្បាស់ហើយ (លោកអធិការឆ្លើយងាកទៅលោកចៅហ្វាយស្រុក) សុំសួរលោក តើការទាំងឡាយដែលត្រូវឱ្យលោកស្មៀនសាលា

វាយម៉ាស៊ីននោះ គឺលោកព្រាងដោយដៃលោកឬក៏ប្រគល់ឱ្យទៅលោកស្មៀនសាលាទាំងអស់ ?

– ការបន្តិចបន្តួច ឬរាយការណ៍ណាដែលគ្មានអ្វីជាលាក់កំបាំង នោះខ្ញុំប្រគល់ឱ្យលោកស្មៀនសាលាព្រាងនឹងវាយម៉ាស៊ីនជាជំនួសខ្ញុំ (លោកវង្គិរិទ្ធិឆ្លើយ) ចំណែកការសម្ងាត់វិញខ្ញុំសរសេរដៃឯង មិនដែលឱ្យវាយម៉ាស៊ីនទេខ្លាចបែកការណ៍ ។

– បើដូច្នោះសុំអនុញ្ញាតិលោក ដើម្បីមើលលិខិតទាំងឡាយដែលបានឆ្លើយមកដោយគំនិតលោកស្មៀននេះមួយភ្លែត ។

– មានអី ! លោកស្មៀនសាលា (ងាកទៅស្មៀននេះ) សុំលោករើយកមកជូនលោកអធិការមើលទាំងអស់ទៅ ។

លុះបានសព្វគ្រប់ហើយ លោកអធិការបើកសៀវភៅសំណៅលិខិតដែលផ្ញើចេញទៅក្រៅមើលមួយសន្លឹកម្តងៗឃើញសេចក្តីសំណៅទាំងប៉ុន្មាន សុទ្ធតែវាយដោយអង្គុលីលេខនៅនឹងក្រដាសស្តើងហើយយកមកបិទ ។ លោកអធិការអានទើសតែចប់មួយសៀវភៅនេះ គ្មានចោលលិខិតណាមួយទេ ។

– លិខិតទាំងឡាយ តើលោកយកសំណៅមកបិទអស់ហើយឬក៏នៅទៀត ? (លោកសួរស្មៀន) ។

– ទានតទៅទៀតមិនទាន់បានបិទទេ ព្រោះប៉ុន្មានថ្ងៃមុននេះរវល់ខ្លាំងពេក (ស្មៀនសាលាយកក្រដាសមួយសំណុំដែលសុទ្ធតែសរសេរដោយពុម្ពអង្គុលីលេខ មកជូនលោកសាវ័ណ្យ) ។



– លោកសាវ័ណ្យធ្វើកិច្ចដដែលតទៅទៀត មួយសន្ទុះស្រាប់តែទាញយកលិខិតមួយច្បាប់មកមើលជិត ហើយហុចទៅបង្ហាញលោកកុម្មីស៊ែរ្យ១ បើកភ្នែកធំៗ មើលទៅលោកស្មៀនសាលា ។

– សំបុត្រនេះលោកធ្វើដោយចិត្តឯងឬក៏អ្នកណាប្រើលោកឱ្យធ្វើ? (លោកកុម្មីស៊ែរ្យសួរស្មៀន) តើធ្វើសំបុត្រអនាមិកៈនេះប្រាថ្នាយ៉ាងណាខ្លះ?

– សំបុត្រអីហ្នឹងលោក ? (លោកស្មៀនសាលាទទួលយកលិខិតដែលលោកកុម្មីស៊ែរ្យហុចមកឱ្យអាន) ទេសំបុត្រនេះខ្ញុំពុំដឹងជាអ្នកណាធ្វើទេ...យិះ! ចំជាសាហាវមែនមនុស្សយើងមានដល់ទីនេះដែរ វាសម្លាប់គេហើយទំលាក់ទោសមកឱ្យឯងទទួលជួសវាទៀត ។

អ្នកណា ? វានោះ ?

– ទេលោក ខ្ញុំឆ្ងល់ណាស់ ចំណែកខ្ញុំគ្មានបានធ្វើយ៉ាងនេះទេ លោកចៅហ្វាយសុគន្ធា មិនដែលមានធ្វើអ្វីឱ្យទាស់ចិត្តខ្ញុំសោះ សូម្បីតែសំដីក៏លោកថ្មមមិនរឱសបានទឹងនរណាផងទេ តើខ្ញុំធ្វើសំបុត្រឆ្កោតនេះប្រយោជន៍អីដល់ជោគវាសនាខ្ញុំ ? ខ្ញុំរកតែចៅហ្វាយនាយចិត្តល្អនេះយូរហើយ មិនដែលឃើញមានសោះ ចុះបើបានលោកសុគន្ធាមកតម្រូវចិត្តខ្ញុំហើយ ខ្ញុំទៅមានចិត្តចង់ព្យាបាទលោកធ្វើអីទៀត? ដូចជាពុំគួរសោះ ។

បើពុំមែនលោកធ្វើទេ តើអ្នកណាទៅវិញ ? មិនអីទេទុកជាលោកធ្វើមែនក៏ដោយ លោកគ្មានទោសអ្វីទេ គេទុកលោកជាទេព្តា បំភ្លឺរាជការឱ្យមើលឃើញការពិតផងត្រូវការអ្វីលាក់ ?

លោកស្មៀនសាលាប្រកែករហូតដោយតឹងមាត់ លុះត្រាតែលោកអធិការសុំឃាត់ ។

ណ្ហើយលោក ! បើមិនមែនលោកធ្វើទេ ខ្ញុំសុំដកយកតែលិខិតតាងនេះទុកប៉ុណ្ណោះចាំខ្ញុំអង្កេតមើលតទៅទៀត (លោកសាវ័ណ្យបទសំណៅសំបុត្រអនាមិកៈ ដែលមានសភាពដូចគ្នានឹងសំបុត្រដើមដាក់ចូលទៅក្នុងហៅចៅ ហើយបបួលលោកកុម្ម៉ីស៊ែរ្យចេញទៅក្រៅ ដើម្បីស៊ើបសួរដល់អ្នកស្រុកផ្សារ) ។

ក្នុងពេលនោះ មានប៉ូលិសសាលាស្រុកបណ្តើរមនុស្សម្នាក់ដែលមានភ្នែកក្រហមហើយពកថ្ងាសមួយដុំ យកមកជូនលោកចៅហ្វាយស្រុក។ មនុស្សអ្នកស្រុកនឹងក្មេងច្រើនលើសលុបដើរតាមមកមើល ។

– ជំរាបប្រសាសន៍ចៅហ្វាយម្ចាស់ (ភ្នាក់ងារប៉ូលិសប្តឹង) អានេះឈ្មោះសៅ ធ្វើជាងដែកនៅចុងផ្សារ ស្រវឹងស្រាកាន់ដំបងដើរវាយកញ្ចក់ទូចិន វាយដបនឹងកែវអ្នកផ្សារដែលលក់លើរានបែកអស់គ្មានសល់ ខ្ញុំប្របាទម្ចាស់ខ្លាចវាតដៃក៏បានដាល់មួយដៃបង្អន់ទៅ ទើបចាប់វាបានយកមកនេះ ។

– យកវាទៅដាក់គុកទៅ (លោកចៅហ្វាយឱ្យបញ្ជា) បីថ្ងៃ បើវាមិនស្វាងស្រវឹងទេដាក់វាបីថ្ងៃទៀត ។

– លោកចៅហ្វាយ ! បើមានការរវល់សុំអញ្ជើញទៅបង្ហើយការ ចុះ (លោកអធិការនិយាយទៅកាន់លោកវង្គិរិទ្ធិ) ទុកឱ្យខ្ញុំធ្វើការនេះតែ



ពីរនាក់លោកកុម្ម៉ីស៊ែរ្យបានហើយ ប៉ុន្តែខ្ញុំសុំកន្លែងមួយស្ងាត់ដើម្បីនឹងសួរចម្លើយ ។

– មើលទៅដូចជាគ្មានកន្លែងណាគួរសមទេ (លោកចៅហ្វាយតប) បើសិនជាលោកអញ្ជើញទៅតាំងកន្លែងនៅហោណាំងមុខផ្ទះខ្ញុំ ប្រហែលជាស្រួលដែរ ចាំខ្ញុំឱ្យប៉ូលិសលើកតុកៅអីទៅដាក់ជូន ។

– បើបានកន្លែងនោះស្រួលណាស់ (រួចលោកងាកមកលោកកុម្ម៉ីស៊ែរ្យ នៅពេលដែលលោកចៅហ្វាយស្រុកដើរចេញទៅចាត់ការ) ខ្ញុំមើលទៅឃើញថាលោកវង្គិរិទ្ធិនេះបែបជាមិនសូវមានធម៌មេត្តាហើយប្រព្រឹត្តខុសច្បាប់ផង លោកមើលអម្បាញមិញនេះ លោកបានឱ្យបង្គាប់ទៅប៉ូលិសឱ្យឃុំមនុស្សទោសបីថ្ងៃគ្មានយកមកសួរចម្លើយយ៉ាងហោច ដើម្បីជូនតុលាការជំនុំជំរះ ច្បាប់ឯណាឱ្យចៅហ្វាយស្រុកឃុំ មនុស្សដល់ទៅបីថ្ងៃ? មិនខុសនឹងបញ្ញត្តិច្បាប់ព្រហ្មទណ្ឌឬរដ្ឋធម្មនុញ្ញទៅហើយ ?

– ប្រហែលជាគេគិតថាធ្វើយ៉ាងនេះ ទើបមានអំណាច (លោកកុម្ម៉ីស៊ែរ្យជូនមតិ) ព្រោះបើគ្មានអំណាចទេ បង្ក្រាបសត្រូវពុំបានទេ ។

– ខ្ញុំព្រោះតែមានធម៌មេត្តាពេក បានជាជោគវាសនាមិនបញ្ជូនខ្ញុំឱ្យបានធ្វើចៅហ្វាយស្រុកសោះ....អើលោក ! លោកមានប្រសាសន៍ថាកាលលោកមកអង្កេតលើកមុនដឹងថាកាលដែលចោរវាចូលលុកសាលាស្រុកនោះ វាបានដោះលែងពួកចោរបួន់បូននាក់ ដែលលោកសុគន្ធាបានចាប់យកមកដាក់គុកពីថ្ងៃឬ ?

– មិនច្បាស់ទេ មិនដឹងជាចោរព្រៃវាបើកឱ្យឬក៏វាចេញដោយរបៀបយ៉ាងណាទេ ដែលគេបានដឹងនោះ គឺថាក្រោយដែលចោរវាចេញ ទៅគេពុំឃើញមនុស្សទោសបួននាក់នោះក្នុងគុកទេ ។

– លោកមានបានពិនិត្យមើលទ្វារគុកទេ ?

– ទេ ! ទ្វារគុកនៅដដែល ឯមេសោចំហរដូចជាមានសោចាក់ពីក្រៅថ្មីៗ ។

– អ្នកណាអ្នកកាន់កូនសោខ្ទោះ នឹងកូនសោទ្វារគុក ?

– ដោយកញ្ចុះថា គឺស្មៀនសាលាជាអ្នកកាន់កូនសោទាំងនោះឯដោយក្រាញ់ថា គឺដោយកញ្ចុះ....

– ទេមិនទំនងត្រង់ថាស្មៀនសាលាកាន់កូនសោគុក នឹងសោខ្ទោះទេព្រោះលោកស្មៀនសាលាកាន់ការក្នុងប៉ុយរ៉ូត្រូវការអ្វីទៅកាន់កូនសោទាំងនោះទៀត. ចុះបើកាន់កូនសោ តើយកសោទៅទុកឯណា? ហ៊ានយកទៅទុកឯផ្ទះឬ ? ផ្ទះនៅឆ្ងាយពីសាលាស្រុកផង មិនមែនទេបើថាដោយកញ្ចុះកាន់នោះប្រហែលជាមែន ។

តែប៉ុណ្ណោះអ្នករាជការក្នុងប៉ូលិសទាំងពីរនាក់ក៏ដើរទៅសង្កេតមើលទ្វារនៃគុកសាលាស្រុកដែលនៅជិតនោះ ឃើញថាធ្វើនឹងឈើយ៉ាងមាំហើយមានមេសោយ៉ាងធំនៅនឹងចុងច្រវាក់ប៉ុនកដៃ ទំនងដូចជាលោកកុម្មីស្ស៊ែរថាទាល់តែមានកូនសោចាក់ពីក្រៅទើបបើករួចមែន ។



លុះលោកដើរទៅដល់ទីដែលចៅហ្វាយស្រុករៀបចំឱ្យលោកនៅនឹងហោណាំងមុខផ្ទះហើយ លោកប្រើភ្នាក់ងារលោកឱ្យទៅអញ្ជើញ លោកស្មៀនសាលាមកសួរចម្លើយជាសម្ងាត់ ។

– សំណុំលិខិតដែលខ្ញុំរកឃើញសំណៅសំបុត្រអនាមិកៈនេះតើលោកដាក់ក្នុងទូចាក់សោរាល់ថ្ងៃឬទេ? ( លោកសាវ៉ណ្យសួរស្មៀន) ។

– បាទចាក់សោរាល់ថ្ងៃនៅពេលដែលខ្ញុំចេញពីសាលា ខ្ញុំបើកម្ដងៗតែនៅពេលដែលខ្ញុំមកធ្វើការនេះ ។

ចុះពេលឈប់ថ្ងៃសៅរ៍-អាទិត្យ ឬថ្ងៃបុណ្យម្ដងៗ លោកមានដែលឱ្យកូនសោមកអ្នកណាចាក់យកអីវ៉ាន់អ្វីៗជាជំនួសលោកទេ ? មានអ្នកណាគេមកសុំយកកូនសោទៅបើកយកម៉ាស៊ីនវាយអ្វីៗទេ ?

គ្មានទេ ! មិនដែលទេ !

ចុះសោខ្ទោះនឹងសោទ្វារគុក អ្នកណាទុក ? កាលដែលលោកសុគន្ធានៅ ?

លោកចៅហ្វាយបានប្រគល់ឱ្យចីដោយកញ្ចុះទាំងអស់ព្រោះចីដោយនេះគាត់ត្រូវមើលការខុសត្រូវចំពោះការសន្តិសុខក្នុងសាលាស្រុក ហេតុនេះហើយបានជាលោកចៅហ្វាយមុនមិនដែលយកទៅធ្វើប្រតិបត្តិការខាងក្រៅជាមួយលោកសោះ ហើយកាលដែលលោកចាប់បានអាចោរបួននាក់មកនោះលោកបានប្រគល់ឱ្យទៅចីដោយកញ្ចុះទុកដាក់ ។

– ចុះឃ្លាំងកាំភ្លើងនឹងគ្រាប់រំសេវ ?

– នោះក៏ត្រូវថិដោយកញ្ចុះទាំងអស់ យកចេញយកចូលទាំងប៉ុន្មាន ត្រូវគាត់មើលត្រួតត្រា ការខុសត្រូវទទួលលើគាត់ គាត់នេះហើយដែលចែកគ្រាប់ឱ្យទៅប៉ូលិសណាប៉ុន្មានៗ ?

បានហើយលោកអញ្ជើញទៅធ្វើការចុះ ខ្ញុំអរគុណហើយ ។

លុះលោកស្មៀនសាលាចុះផុតទៅ :

– ខ្ញុំមើលឃើញហើយ (លោកអធិការបង្ហាញមតិ) គឺមិនមែនស្មៀននេះទេដែលធ្វើសំបុត្រអនាមិកៈ ព្រោះរបៀបសរសេរមិនមែនត្រូវគ្នាទេ លោកស្មៀននេះមានចំណេះប្រហែលពួកសិស្សថ្នាក់ឧត្តមដ្ឋាន ចំណែកសំបុត្រអនាមិកៈជាស្នាដៃអ្នកមានចំណេះខ្ពស់ជាងទៅទៀត ប៉ុន្តែបោះពុម្ពដោយអង្គុលីលេខសាលាស្រុករវៀងនេះប្រាកដហើយ ។

– បើដូច្នោះមានតែអ្នកនិពន្ធនោះជាអ្នកធ្វើការក្នុងសាលាជាមួយមើលលោក ! សុំមើលកាលបរិច្ឆេទមើល ? ធ្វើពីថ្ងៃណា ?

– គឺធ្វើពីថ្ងៃដែលកើតហេតុរួចមួយថ្ងៃ តាំងពីលោកវឌ្ឍិទិទ្ធិនៅឯកំពង់ធំនៅឡើយ ប៉ុន្តែកាលបរិច្ឆេទនេះមិនទៀងទេ គេដាក់ទុកជាមុនក៏បាន គេដាក់ក្រោយក៏បាន ។

– មានអ្នកណាចេះជាងលោកស្មៀនសាលា ? បើថាលោកយោក្ប៊ត ក៏លោកពុំមែនចេះភាសាជាន់ថ្មីនេះដែរ ។

– ប៉ុណ្ណឹងចុះ យើងទុកបញ្ហានេះមួយអន្លើសិន ហើយនាំគ្នាពិចារណាមើលតើដែលថាអាចោរវាចេះរបៀបបញ្ជៀសគ្រាប់បណ្តាលឱ្យលោកសុគន្ធា នឹងពួកប៉ូលិសបាញ់វាពុំត្រូវនោះ តើជាការពិតមែនឬអ្វី?



– មតិខ្ញុំថាត្រង់បាញ់វាពុំស្លាប់នោះជាការពិតណាស់ព្រោះបាញ់វាអស់គ្រាប់សន្ធឹកណាស់បានមនុស្សតែបួននាក់ ឯត្រង់ថាអាចោរវាចេះមន្តអាគមនោះ មិនដឹងវាម៉េចទេ ។

– ចុះបើយើងថាលោកសុគន្ធាបាញ់បង្ហុសទៅ ?

– បាញ់បង្ហុសប្រយោជន៍អ្វី? ស្មានថាលោកសុខចិត្តស្រឡាញ់ជីវិតគេជាជាងជីវិតលោកនឹងប្រពន្ធកូនលោកទៅឬ?

– នេះហើយ ដែលខ្ញុំថាសំបុត្រអនាមិកៈនេះជាប្រដាប់ពោលក្លែង ។ មួយទៀតបើលោកសុគន្ធាមិនមែនក្បត់ផែនដីទេមានតែគេក្បត់លោក ។

– ក្បត់ដោយរបៀបណា ?

– នេះហើយជាបញ្ហាដែលយើងត្រូវរកកុំបង្អង់...(លោកសាវីណ្យយកបារីមកចែកគ្នាជក់អស់មួយនាទី ទើបសន្ទនាតទៅទៀត)... មែនហើយលោកបានចាត់ការឱ្យរើសសំបកគ្រាប់កាំភ្លើងដែលគេបានបាញ់គ្នានេះទេ? កាលលើកមុន ? ។

– ថ្វីក៏គ្មាន រើសបានច្រើនផង

– លោកមានបានពិនិត្យមើលឱ្យជាក់ហើយមានរាប់មើលទេ ?

– ខ្ញុំបានរាប់មើលឃើញសំបកគ្រាប់កាំភ្លើងជប៉ុនម្ភៃប្រាំពីរសំបកគ្រាប់បារាំងដែលចែកឱ្យសាលាស្រុកប្រើសាមសិបប្រាំ ក្រៅពីនោះសុទ្ធតែជាគ្រាប់ចំឡែក ខ្ញុំមិនដឹងជាធ្វើពីស្រុកណាមកទេ មានរូបរាងដូចគ្រាប់បារាំងដែរ ប៉ុន្តែលុះពិនិត្យមែនទែនទៅ ទើបដឹងថាមិនមែនជាគ្រាប់ បារាំងគ្រាប់បែបនេះឃើញសំបកដល់ទៅបីរយហុកសិបពីរ ។

– ចុះគ្រាប់ដែលចេញពីសំបកនោះរើសបានប៉ុន្មានទៅ ?

– រើសបានតែគ្រាប់ជប៉ុនប៉ុណ្ណោះ គ្មានរើសបានគ្រាប់បារាំង ឬ គ្រាប់ដែលមានសំបកចំឡែកនោះទេ ។

– យី ! ពតិមាននេះនាំឱ្យខ្ញុំសង្ស័យខ្លាំងណាស់ថាមានមនុស្សក្បត់ពិតៗ... គឺមនុស្សរបស់លោកសុគន្ធាដែលទាស់ហេតុអ្វីនឹងលោក បែរទៅចូលដៃនឹងពួកចោរ នាំឱ្យលោកសុគន្ធាចាញ់ដៃចោរដោយងាយ ឯរបៀបក្បត់នោះគឺរឿងគ្រាប់កាំភ្លើងទាំងនេះឯង ! លោកគិតមើល ប្រហែលអាហ្គីងវាយកគ្រាប់រំសេវទទេដែលមានរូបរាងដូចគ្រាប់ដែលធ្លាប់ប្រើពីចោរមកដូរយកគ្រាប់បារាំងទៅឱ្យចោរវិញ ប៉ុន្តែចោរវាមិនប្រើគ្រាប់បារាំង វាយកតែគ្រាប់ជប៉ុនមកបាញ់ក៏បានហើយ សំបកគ្រាប់ជប៉ុនដែលតិចនេះ គឺរបស់ចោរដែលបាញ់បន្តិចបន្តួចព្រោះបានដឹងរបៀបរៀបចំរបស់មនុស្សទុច្ចរិតរួចហើយវាបាញ់មួយគ្រាប់ឬពីរគ្រាប់ពីចម្ងាយទៅ ពួកប៉ូលិសបាញ់ទៅគ្មានសំចៃ- ខ្ញុំគិតឃើញថាអាក្បត់វាប្តូរគ្រាប់ល្អដាក់គ្រាប់រំសេវទទេនោះនៅពេលថ្ងៃ លុះពេលយប់ដែលពួកចោរមិនទាន់មកដល់នោះ ពួកប៉ូលិសមាននៅសល់គ្រាប់មែនទែនតាំងពីថ្ងៃមកដាក់ចូលក្នុងកាំភ្លើងរួចស្រេច លុះមានអាសន្នក៏ទៅយកគ្រាប់ថែមពីឃ្លាំងមកការពារ តែលើគ្រាប់បាញ់មិនស្លាប់តែម្តង ។ គ្រាប់បារាំងល្អៗ ពួកប៉ូលិសបាញ់មុនដំបូងពីក្នុងទៅក្រៅអស់ ហេតុនេះហើយបានជាគេគ្មានរើសបានគ្រាប់បារាំងនៅជិតៗនោះសោះ ។ អាចោរវាចាំស្តាប់សូរលុះកាលណាអស់គ្រាប់មែនទែនពីកាំភ្លើងហើយៗ ពួបាញ់តែគ្រាប់ក្លែងក្លាយ



ទើបពួកចោរវាចូលលុកធ្វើហី ពួកប៉ូលិសបាញ់តែគ្រាប់ក្លែងក្លាយធ្វើម្តេចត្រូវវាស្លាប់ ? វាបាញ់តែគ្រាប់ជប៉ុនក៏ត្រូវពួកប៉ូលិសស្លាប់គ្មានខាតមួយគ្រាប់ ដូច្នេះបានជាគេរើសបានតែសំបកគ្រាប់ក្លែងក្លាយ ។

– ចុះលោកសុគន្ធា ម្តេចក៏បាញ់ស្លាប់បានបួននាក់នៅលើផ្ទះលោក ?

– លោកបានមានប្រសាសន៍ប្រាប់ខ្ញុំថា តាមចំឡើយដោយក្រាញ់អាចោរចូលមកដល់ខាងមុខផ្ទះនេះហើយ លោកចៅហ្វាយបើកទ្វារកាន់មីត្រៃយ៉ែតទៅបាញ់វា តើបាញ់មានស្លាប់គ្នាវាឯណា ? បើខាងក្រៅមិនស្លាប់ ចុះម្តេចក៏បាញ់ក្នុងផ្ទះស្លាប់គ្នាវា? ខ្ញុំនឹកស្មានទៅប្រហែលជាកាំភ្លើងមីត្រៃយ៉ែតនេះគេទើបនឹងយកមកជូនលោក ឬក៏អាក្បត់វាលួចប្តូរគ្រាប់ទុកជាស្រេចហើយបានជាបាញ់មិនបានការសោះយ៉ាងនេះ ឯបាញ់ខាងក្នុងផ្ទះវិញប្រហែលជាលោកយកកាំភ្លើងស្មៀតបាញ់វាវទេ ឯកាំភ្លើងស្មៀតនេះជាអាវុធផ្ទាល់ខ្លួនរបស់លោក មានអ្នកណាទៅផ្លាស់ប្តូរអ្វីបាន? ទៅណាយកតាមជាប់នៅខ្លួន ហេតុនេះហើយបានជាបាញ់បានផលនោះ ។

– លោក ! សម្មតិកម្មលោកនេះសមណាស់យើងនៅតែផ្ទៀងមើលតទៅទៀតប៉ុណ្ណោះ ឯកិច្ចដែលផ្ទៀងនេះពិបាកណាស់ ព្រោះសាក្សីទៅបាត់អស់រលីង ។

## ជំពូក៧

## រស្មីខ្លះ

លោកអធិការបានសួរចម្លើយអ្នករាជការសាលាស្រុកគ្រប់គ្នាម្តងម្នាក់ៗ គេឆ្លើយត្រូវគ្នាថាគឺដោយកញ្ចុះជាអ្នកកាន់កូនសោខ្ទោះដៃមនុស្សទោស នឹងកូនសោទ្វារគុក ហើយជាអ្នកត្រូវទទួលខុសត្រូវចំពោះឃ្លាំងគ្រាប់រំសេវនឹងកាំភ្លើង ។

បណ្ឌូតបានបញ្ជាក់ថាខ្លួនឃើញច្បាស់ជាដោយកញ្ចុះនេះទទួលអាចោរបួននាក់យកទៅដាក់គុក ហើយឃើញដោយកញ្ចុះនិយាយនឹងមនុស្សទោសខ្សឹបៗ មិនដឹងជានិយាយអ្វីខ្លះទេ ។

ហ្នំ... ចំឡើយទាំងនេះដូចពេលស្មៀនសាលាឆ្លើយដែរ (លោកកុម្មីស្ស៊ែរលាន់មាត់) ចុះក្រៅពីលោកធ្វើការ អ្នកឯងមានបានឃើញអ្នកណាមកវាយម៉ាស៊ីនម្តងណាទេ ?

មានអ្នកណា (បណ្ឌូតឆ្លើយ) អុះមែន ! ខ្ញុំបានឃើញចីដោយកញ្ចុះមកអង្គុយវាយម្តងខ្ញុំសួរថាវាយអី? គាត់ថាគាត់រៀនវាយលេង ។

– អ្នកមានសួរថាបានកូនសោពីណាមកចាក់ទូម៉ាស៊ីននេះទេ ?

– ខ្ញុំបាទសួរដែរគាត់ថាគាត់បានខ្ចីពីលោកស្មៀនសាលាមក ។

– អ្នកឃើញពីថ្ងៃណា ?

– ទានខ្ញុំឃើញពីថ្ងៃអាទិត្យមុនម្ល៉េះ



(លោកកុម្មីស្ស៊ែរមើលមុខលោកអធិការហើយពោល)

– លោកមើល ! លោកស្មៀនសាលាថាមិនដែលបានឱ្យអ្នកណាខ្ចីកូនសោទេ ចុះដោយកញ្ចុះបានសោពីណាមកចាក់ ។

– អានេះវាបានប្រុងមកយូរហើយៗ ដាក់កាលបរិច្ឆេទឱ្យហើយទៅ ប៉ុន្តែខ្ញុំឆ្ងល់ណាស់ ប្រហែលជាដោយនេះមានកូនសោមួយដោយ ខ្លួនចាក់យកម៉ាស៊ីនវាយសំបុត្រអនាមិកៈនេះទេដឹង ?

– សូមទោស (បណ្ឌូតកាត់) ខ្ញុំបាទបានឃើញដោយកញ្ចុះនេះបានហៅជាងមកសាលាស្រុកម្តង ប៉ុន្តែមិនដឹងឱ្យធ្វើអ្វីសុំលោកសួរបញ្ជាក់ជាងនោះមើល ? វានៅហ្នឹងស្រាប់តើ ។

– នៅឯណា ? (លោកអធិការសួរ) ។

– ទាននៅក្នុងគុកនេះ ប៉ូលិសទើបនឹងចាប់យកមកអម្បាញមិញ ។

– យើងគិតសួរដោយកញ្ចុះសិនឬ ? (លោកកុម្មីស្ស៊ែរសួរ)

– ទេលោក (អធិការតប) យើងប្រមូលភស្តុតាងឱ្យបានច្រើនសិនចាំសួរវាឱ្យបានការតែម្តង មើលទៅអានេះហើយជាមនុស្សក្បត់គ្មានអ្នកណាទៀតទេ ។

– បើដូច្នោះមានតែឱ្យភ្នាក់ងារយើងទៅហៅវាមកឃាត់ទុកសិនទៅក្រែងវារត់បាត់ ។

– មិនអីទេ យើងធ្វើកុំឱ្យវាដឹងខ្លួន បើវារត់ក៏រត់ចុះ ទុកឱ្យខ្ញុំៗនឹងប្រើតិរិះខ្ញុំឱ្យពេញទីម្តង ។

លុះភ្នាក់ងារប៉ូលិសជាតិបានទៅនាំជាង «សៅ» មកដល់ហើយ ក្រោយដែលបានសុំអនុញ្ញាតលោកចៅហ្វាយស្រុករួចស្រេចបួលលោកសួរជាងសៅថា ។

– អ្នកឯងធ្វើជាងអីសព្វថ្ងៃ ?

– យ៉... កុំនិយាយលេង... (ជាងសៅមិនឆ្លើយតាមសំនួរគេ





បែរជានិយាយក្រទីក្រទាតែពាសវាលពាសកាល)... ហាងឯងជាំបាយមិនឆ្អិនអញធាក់ហាងរកពុទ្ធោ....

– នែ ! អ្នកឯងស្រវឹងស្រាទេឬ ? បើប្រាកដជាស្រវឹងយើងសួរតាមមនុស្សស្រវឹង ។

– ព្រះស្តែងក៏ឡូយម្ល៉េះ...ធ្វើហ្លួងឬ ?....មកសួរអញ....

– នែ ! ឈប់ធ្វើជាស្រវឹងទៅបើអ្នកមិនមែនស្រវឹងទេ អ្នកឯងដឹងទេ យើងមិនមែនសួរអ្នកឯងលេងទេ យើងជាតិព្វណ៉ា ! សួរអ្នកឯងយកការហើជាប្រយោជន៍ប្រទេសណ៉ា !

ជាងសៅឮសំដីនេះភ្លាមទាញទឹកមុខឱ្យបានដូចមនុស្សធម្មតាភ្លាមលុតជង្គង់ចុះលើកដៃសំពះ ។

– ព្រះតេជព្រះគុណអើយជួយខ្ញុំបាទផង (ជាងនេះពោលបន្ទាន់គ្នានឹងកាយវិការលោកអធិការដែលចាប់ទាញដៃឱ្យក្រោកឈរឡើង) ខ្ញុំបាទឃើញព្រះតេជព្រះគុណនេះដូចជាបានឃើញអ្នកមានបុណ្យមកប្រោសមនុស្សលោក ។

– យ៉ាងម្តេចអញ្ចុះ ? យើងប្រាប់អ្នកថាកុំឱ្យធ្វើជាស្រវឹងទៀតណ៉ា! ព្រោះទឹកមុខអ្នកមិនមែនជាអ្នកស្រវឹងទេ ។

– ានទេ ! ខ្ញុំបាទគ្មានស្រវឹងទេ កាលមុនខ្ញុំធ្វើមែនលុះដឹងជាលោកនៅក្នុងក្រសួងតិព្វមកស៊ើបការណ៍នេះខ្ញុំគ្មានធ្វើជាស្រវឹងទេ សូមលោកជ្រាបថា អាយុជីវិតខ្ញុំកំពុងមានអាសន្ន បើលោកមិនជួយស្រោច

ស្រង់ទេ ខ្ញុំស្លាប់ភ្លាមដោយហេតុថាតាំងពីពីរបីថ្ងៃនេះមានមនុស្សដើររក តែរូបខ្ញុំបាទនឹងសម្លាប់ចោលទាន...

– សម្លាប់រឿងអ្វី ?

– ពុំដឹងរឿងអ្វីទេ ខ្ញុំបាទខំតែគេចខ្លួនក្នុងផ្សារនេះ មិនហ៊ានទៅណាឆ្ងាយ ព្រោះក្រៅពីផ្សារគឺចូលក្នុងដែនវាៗ នេះជាចោរព្រៃពិតៗ ។

– ចុះលោកចៅហ្វាយស្រុកមានដែរ ម្ដេចក៏មិនមកជំរាបឱ្យគេទៅចាប់វាទៅ ?

– ទានមកប្ដឹងចៅហ្វាយស្រុកនេះទុកដូចជាយកមករុញចូលម៉ាស៊ីនតែម្ដង ។ ព្រោះអាមនុស្សនោះ ខ្ញុំបាទធ្លាប់ឃើញវាមករាប់អានចីដោយកញ្ចុះស្និទ្ធស្នាលណាស់ ចិត្តមួយថ្លើមមួយ ធ្វើម្ដេចនឹងខ្ញុំហ៊ានចូលសាលាស្រុក ? យប់មិញវាតាមខ្ញុំកិតណាស់ ខ្ញុំបាទខំគេចនឹងវាមើលទៅពុំរួចទេទាល់ច្រកហើយ ទទួលខ្ញុំបាទឃើញពួកទាហានថ្មីៗ មកដល់សាលាស្រុកដូច្នេះ ក៏ខ្ញុំបាទដាច់ចិត្តថាបើមកនៅក្នុងគុកប្រហែលជារួចពីកណ្ដាប់ដៃវាដែរ មួយទៀតខ្ញុំដឹងដំណឹងថាពីព្រឹកមិញនេះលោកចៅហ្វាយបានប្រើចីដោយកញ្ចុះឱ្យទៅអង់ទូរលោផុតទៅហើយ ធ្វើយ៉ាងនេះបើនឹងស្លាប់ក៏ស្លាប់ឱ្យគេដឹងឮ គេនឹងស្រួលរកវាអាមនុស្សឃាតក ខ្ញុំទុកចិត្តថា ខ្ញុំនៅក្នុងគុកនេះ អាចោរព្រៃដែលតាមរកសម្លាប់ខ្ញុំបាទនោះ វាមិនហ៊ានចូលមកដោយចិត្តវាទេ បើវាចូលមកសម្លាប់ខ្ញុំបាទបាន មានតែអ្នកយាមខ្ញុំវាសមគំនិតជាមួយផង ។ រាជការនឹងស្រួលរកជាទីបំផុត ។

– ខ្ញុំឆ្ងល់ណាស់គេរកសម្លាប់អ្នកមកពីរឿងហេតុអ្វី ?



– ទានខ្ញុំបាទរកនឹកពុំឃើញសោះ ។

– ល្ហើយអំពីរឿងអ្នកនោះកុំអាលសិន ចាំយើងសួរការណ៍ដែលយើងត្រូវការសួរសិន ។

– ការណ៍អីទៀតហើយលោក ?

– អ្នកឯងមានមកធ្វើសោនៅសាលាស្រុកម្ដងមែនទេ ?

– ទានមែន កាលនោះយូរហើយ គឺនៅថ្ងៃអាទិត្យមិនដឹងប៉ុន្មានអាទិត្យមកហើយទេ ចីដោយកញ្ចុះបានទៅហៅខ្ញុំថាសាលាស្រុកបាត់កូនសោមួយចង្កោម រកអីបើកគម្របម៉ាស៊ីនពុម្ពលើទូដែលជាប់នឹងតុនោះពុំបានទេ សុំជួលឱ្យខ្ញុំបាទធ្វើកូនសោថ្មីទៀត ខ្ញុំបាទធ្វើជាងដែកស្រាប់ពិតមែនតែមិនដែលធ្វើកូនសោទេ ប៉ុន្តែខំខ្នះខ្នែងជួយធ្វើ ចង់យកគាប់លោកចៅហ្វាយក្រែងបានសេចក្ដីសុខដោយសារម្លប់របស់លោក ។

– កូនសោថ្មីៗ ទាំងនោះអ្នកបានប្រគល់ឱ្យទៅអ្នកណាហើយ ?

– ទានប្រគល់ឱ្យទៅចីដោយកញ្ចុះទាំងអស់ ក្រោយមកគាត់ប្រាប់ថាលោកចៅហ្វាយសប្បាយចិត្តនឹងខ្ញុំបាទណាស់ ។

– ចុះមនុស្សដែលរកសម្លាប់អ្នកនោះនៅទីណាឥឡូវ ? អ្នកនាំពួកយើងទៅចាប់វាបានទេ ?

– ខ្ញុំបាទមិនដឹងទេ ? វាជាមនុស្សមកពីចម្ងាយ ប៉ុន្តែឃើញវាតែម្ដងៗប៉ុណ្ណោះ ចីដោយកញ្ចុះបាននាំទៅផឹកស្រានឹងទៅលេងផ្ទះខ្ញុំបាទគិតជួលខ្ញុំបាទធ្វើអីមិនដឹងទេពីយប់មិញ ខ្ញុំបាទទៅពួនក្នុងព្រៃក្បែររបងឃើញវាទៅសួរប្រពន្ធខ្ញុំបាទរករូបខ្ញុំបាទ ?

– បើមិនដឹងវានៅឯណា ធ្វើម្ដេចទៅរកវាឃើញ ? យើងទៅរកតែពាសទៅតិចវាលបបាញ់ឯងស្លាប់ក៏មិនដឹង ។

– ខ្ញុំសន្និដ្ឋានបានហើយ ( លោកកុម្មីស្ស៊ែរជូនយោបល់នៅពេលដែលគេនាំជាងសៅទៅគុកវិញ ) ថាមនុស្សដែលក្បត់លោកសុគន្ធានោះគឺដោយកញ្ចុះនេះប្រាកដ ឯមនុស្សដែលធ្វើសំបុត្រអនាមិកៈក៏មនុស្សនេះទៀត....

– មែនហើយលោក ( មតិលោកសាវ័ណ្យ ) អាក្បត់នោះគឺច្បាស់ណាស់ អំពីសំបុត្រអនាមិកៈនេះគ្រាន់តែដឹងថាមនុស្សនេះបានវាយម៉ាស៊ីនប៉ុណ្ណោះ ប៉ុន្តែមិនដឹងជាអ្នកណាព្រាងឱ្យព្រោះសេចក្ដីដែលសរសេរនេះជាស្នាដៃរបស់មនុស្សចេះដឹង

– ក្រែងកូនវាធ្វើឱ្យទេឬ ? យើងនិយាយស្មានទៅចុះក្រែងមានផ្លូវនឹងដើរបានទៀត

– ទំនងណាស់លោក ប៉ុន្តែកាលវាវាយសំបុត្រនេះគឺវាយតាំងពីមុនលោកវង្គិរិទ្ធិមកកាន់កាជាចៅហ្វាយស្រុកនៅរវៀងនេះម្ល៉េះ ។

– ក្រែងតែវាឱ្យកូនវាសរសេរព្រាងតាំងពីនៅកំពង់ធំ ហើយផ្ញើមកឱ្យវាយូរមកហើយ តាំងពីមុនកើតកលិយុគនេះម្ល៉េះទេដឹង

– ធ្វើម្ដេចនឹងផ្ទៀងរកការពិតបាន ?

– ចាំយើងទៅរកមើលឯសាលាខេត្តកំពង់ធំ ក្រែងមានឯកសារអ្វីដែលលោកវង្គិរិទ្ធិធ្វើដោយគំនិតឯង យើងនឹងផ្ទឹមមើល...ទេ ! បើយើងរកឥឡូវទៅមិនបានឬ ? ខ្វះអ្វីសំណៅសំបុត្រដែលលោកនេះបានធ្វើ ?



– ទេលោក ករណីយកិច្ចយើងត្រូវលាក់សេចក្ដីសង្ស័យរបស់យើងទៅលើដោយកញ្ចុះនឹងលោកវង្គិរិទ្ធិសិន កុំឱ្យបែកការ តែបែកការទៅមើលទៅធ្វើអ្វីមិនកើតទេមុខជាវារត់ចូលព្រៃឬក៏ធ្វើឱ្យយើងមានភ័យ-អន្តរាយជាមិនខានក្នុងពេលនេះ ។

– មែនហើយ អើយើងត្រូវរកខត្រង់នេះទៀតគឺរកត្រង់ហេតុយ៉ាងណាដែលមនុស្សអាក្រក់នេះវាដាច់ចិត្តក្បត់លោកសុគន្ធា ?

– ការនេះងាយទេ ប៉ុន្តែស្ដាយណាស់ពេលយើងនៅសល់តិចពេកនឹងឆ្លៀតរកពុំកើត ដើម្បីបំពេញកិច្ចនេះត្រូវតែដេកមួយយប់ ហើយដើរស៊ើបដល់អ្នកស្រុករវៀងនេះទៅដឹងហើយ បើចង់ដឹងឱ្យច្បាស់ត្រូវសួរអ្នកស្រុកណាដែលធ្លាប់មានរឿងកើតក្ដី ឡើងដល់សាលាស្រុក ហើយលោកសុគន្ធាបានសំរេចយ៉ាងណាៗ ហើយយើងយកមកពិចារណាទៅជាការងាយបំផុត គឺចាំតែដោយកញ្ចុះត្រឡប់មកពីតួរណេវិញយើងយកមកសួររកឯលិចឯកើតតាមឧបាយ មើលទៅតង់តែនឹងលេចទេ ។

– លោកមានប្រសាសន៍នេះត្រូវណាស់មុខការចៅហ្វាយស្រុកនេះមួយ ចាងហ្វាងឬសុភានេះមួយពិបាកណាស់ក្នុងរឿងក្ដីនិមួយៗ សុទ្ធតែមានមនុស្សទាស់ចិត្តម្នាក់ ទុកជាធ្វើល្អកាន់យុត្តិធម៌យ៉ាងណាក៏ដោយមិនមែនតម្រូវចិត្តមនុស្សគ្រប់គ្នាទេ ។ នេះប្រហែលជាពួកមនុស្សទុច្ចរិតដែលបានរួមគំនិតជាមួយនឹងដោយកញ្ចុះ ដើម្បីដើរសង្កត់កគេយកប្រយោជន៍នោះវាខឹងនឹងលោកសុគន្ធាចាប់វា ឬសំរេចឱ្យខុសពីបំណងរបស់វា....។

ព្រះសុរិយា ដែលខំក្នុងការកំដៅប្រថពីឱ្យរណ្ដោះពីធាតុរងាខែកត្តិកតាំងពីពេលព្រឹកមកនេះ បន្ថយល្បឿនបណ្ដោយអង្គកាយឱ្យអណ្ដែតដោយឯងៗ ទៅកាន់ជើងមេឃខាងលិច ដោយបានជ្រកជ្រៀតក្នុងអ័ព្ទយ៉ាងក្រាស់ ។ នៅពេលដែលលោកកុម្មីស្ស៊ែរប្រមូលទាហានរៀបចំនឹងធ្វើដំណើរត្រឡប់ទៅកំពង់ធំវិញនោះ លោកសាវីណ្យអញ្ជើញទៅជួបនឹងលោកចៅហ្វាយស្រុកវង្គិរិទ្ធិ ដើម្បីសុំសើរើមើលសំណុំរឿងដែលលោកសុគន្ធាបានធ្វើក្នុងរវាងបី ឬបួនថ្ងៃមុនកើតហេតុ ។ លោកភ្ញាក់ឈ្មោះអ្នកក្ដីគ្រប់គ្នា រួចសុំលាលោកចៅហ្វាយស្រុកតែម្ដង ។ លោកកុម្មីស្ស៊ែរក៏ទៅជួបលោកវង្គិរិទ្ធិនៅប៉ុយរ៉ូហើយលាលោកមកកំពង់ធំវិញដែរ ។

– ការស៊ើបសួររបស់ខ្ញុំ (លោកអធិការឆ្លើយនូវសំនួរជាធម្មតារបស់លោកវង្គិរិទ្ធិ) គ្មានបានការអ្វីសោះទេ ព្រោះលោកនាយកអនុញ្ញាតពេលឱ្យខ្ញុំតិចពេក បើបានការគឺបានត្រង់រកឃើញអ្នកនិពន្ធសំបុត្រអនាមិកៈដែលផ្ញើទៅប្ដឹងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប៉ុណ្ណោះ ។ លោកជ្រាបស្រាប់ហើយគ្មានហួសពីមនុស្សដែលខ្ញុំចាប់បានភស្តុតាងលើដៃវានោះទេ ប៉ុន្តែសុំលោកមេត្តាធ្វើកុំឱ្យវាដឹងខ្លួន មួយទៀតមើលទៅរាជការគេមិនមែនរកទោសរកហេតុអ្វីនឹងអ្នកដែលសរសេរនោះទេ ព្រោះសេចក្ដីដែលប្ដឹងនោះប្រហែលជាការពិតដែរ អត់ទោសសុំលោកបំភ្លឺខ្ញុំបន្តិច តាំងពីលោកមកកាន់ការជាចៅហ្វាយស្រុកនេះលោកមានបានការអ្វីពីលោកសុគន្ធាទេ ?

– ការដែលខ្ញុំដឹងនោះ (លោកវង្គិរិទ្ធិតប) យកជាការហ្មត់ចត់ពុំបានទេ ព្រោះជាពាក្យចចាមអារាមស្មោះ ពាក្យនោះគេថាលោកសុគន្ធា



រត់ទៅស្រុកសៀមបាត់ទៅហើយឯកូនក្រមុំលោកៗ បានលើកទៅឱ្យមេចោរក្នុងព្រៃ ។

ក្រោយពីសន្ទនាជាទីបង្ហើយនេះ ភ្ញៀវទាំងឡាយនៃលោកចៅ-ហ្វាយស្រុកធ្វើដំណើរពីផ្សាររវៀងត្រឡប់ទៅកំពង់ធំវិញដោយហែជាក្បួនដដែលហើយប្រើល្បឿនអស់លេខហាក់ដូចជាប្រញាប់ខ្លាំងណាស់ ។

*****

## ជំពូក៨

## ដោយគ្រាញ់

ថ្ងៃបន្ទាប់មក ពេលព្រលឹមស្រាង១ គេសង្កេតឃើញបុរសម្នាក់ក្នុង
វ័យក្មេងនៅឡើយស្លៀកខោវែងខ្មៅ ពាក់អាវចិនខ្មៅយ៉ាងចាស់រហែក
រយីករយាក ដើរកាត់អ័ព្ទយ៉ាងក្រាស់ដែលគ្របដណ្តប់ពសុធាទាំងមូល ។
ស្មាវាខំរែកអង្ករពីរកញ្ជើយ៉ាងធ្ងន់ ។ ដៃស្តាំវាបោះទៅមុខគងលើដងរែក
ឯដៃឆ្វេងកំបុតនៅសល់តែគល់បន្តិចយោលសំពត់ដៃអាវខ្វៃៗខ្វៃៗ ។ ទោះបិ





បុរសនេះដើរកាត់ផ្សាររវៀងតាមផ្លូវណាៗក៏ដោយ គ្មាននរណាគេ ទឹកភ្នកសួរ
តើវានៅស្រុកភូមិណា ហេតុយ៉ាងណាបានជាកំបុតដៃយ៉ាងនេះ
ហើយម្តេចក៏មិនដើរសុំទានគេ បែរជាមកត្រដររែកអង្ករត្រដេបត្រដាបយ៉ាង
នេះ ។ ប្រហែលជាគេស្មានថា ជាអ្នកស្រែធម្មតាដែលគេធ្លាប់ឃើញមកលក់
ដូររាល់ព្រឹកក៏មិនដឹង ។ លុះរែកអង្ករមកដល់ខាងមុខសាលាស្រុក ក៏បុរស
នេះដាក់អម្រែកចោលទៅដី ឈរដកដង្ហើមញាប់ដើម្បីប្រមូលយកកំលាំង
ដែលអស់តាមផ្លូវ ។ ភ្នែកវាគ្មានងាកចេញពីស្ត្រីកណ្តាល មនុស្សម្នាក់ដែល
បររទេះគោមួយទទេ ហើយដែលមើលទៅលិចទៅកើត ឆ្វេឆ្វាតែម្នាក់ឯង ។
លុះឃ្លូវបន្តិចឃើញស្ត្រីនេះបររទេះបកទៅវិញ ហើយតម្រង់ក្បាលទៅ
ឧត្តរទិសក៏បុរសចាប់អម្រែកខំដើរយ៉ាងលឿនឱ្យ បានទាន់រទេះនោះ ។

– មីង ! បររទេះទៅណា ? (វាសួរ) ម្តេចក៏គ្មានដឹកអ្វីសោះ?

– ទេខ្ញុំមក មានត្រូវការដឹកអ្វី ? (នារីឆ្លើយ) ខ្ញុំមករកប្តីខ្ញុំតើ
បាត់មិនឃើញទៅផ្ទះសោះតាំងពីយប់មិញម្ល៉េះ? កូនខ្ញុំវាបាក់ដៃពីល្ងាចមិញ
មានអ្នកណាគេទៅរកគ្រូហ៊្មឱ្យ ?

– យី បាក់ខ្លាំងទៅឬ ?

– ចា៎ះ វាដេញក្របីបញ្ចូលក្រោលក៏ជំពុបជើងដួលច្រត់ដៃទៅដី ។

– រួចចុះមីងឯងនៅដល់ណា បានជាចាំបររទេះមក ?

– ខ្ញុំនៅដល់ភូមិកំពង់ពុទ្រាឯណោះទេ ប៉ុន្តែប្តីខ្ញុំណា៎ះ គេប្រាប់ខ្ញុំ
ថាលោកចៅហ្វាយឱ្យហៅមកសាលាស្រុកគេមកក៏បាត់ដំណឹងសូន្យទៅ ។

– ប្តីមីងឯងធ្វើអីដែរ បានជាលោកចៅហ្វាយលោកហៅមក ?

– ទេគ្មានធ្វើអ្វីទេ ប៉ុន្តែប៉ុន្មានថ្ងៃនេះឃើញលោកសក្តិបីកញ្ចុះដែល ពីដើមធ្វើប៉ូលិសសាលាស្រុក ឧស្សាហ៍មកបបួលគេហ៍ដើរលេងហាក់ដូច ជាពួកម៉ាកដូច្នេះ ។

– ....( បុរសឆ្ងល់ណាស់ តើដោយកញ្ចុះពាក់សក្តិបីពីកាលណា? ធ្វើដោយប៉ូលិសពីថ្ងៃណោះសោះ ឥឡូវលោកទៅពាក់សក្តិបី. ដូចជាមិន ដែលមាន ប៉ុន្តែនឹកថាបើតាមនាងនេះបន្តិចទៀត ប្រហែលជាដឹងច្បាស់ វាក៏ខំតមាត់មិនសួរត្រង់ខដែលឆ្ងល់នោះទេ ទុករកឱកាសស្រួល) ប្តីមីងឯង ឈ្មោះអី. ក្រែងលោខ្ញុំបានឃើញដែរ ។

– ឈ្មោះ តា-ចាន់ណ៎ាក្មួយៗ មានឃើញទេ? អាណិតប្រាប់មីងផង

– ទេដូចជាមិនប្រទះ....

– ចុះលោកសក្តិបីកញ្ចុះ ក្មួយឃើញនៅត្រង់ណាទេ ?

– លោកសក្តិបីកញ្ចុះ ? ខ្ញុំឮគេថាលោកទៅអង់ទួរណេពីព្រឹកមិញ ដឹងជាមែនឬពុំមែន....

– ទៅទីណាទៅក្មួយ ?

– ខ្ញុំមិនដឹងទេ ប៉ុន្តែណ្ហើយចុះខ្ញុំធ្វើបុណ្យទៅចុះកំពង់ពុទ្រាឆ្ងាយឬ ជិតខ្ញុំសុំខ្លួនទៅមើលកូនមីងឯងឱ្យ ព្រោះខ្ញុំចេះមើលបន្តិចបន្តួចដែរ ជួយ សង្គ្រោះគេបានច្រើនណាស់ហើយ ។

– បើបានដូច្នោះ ខ្ញុំអរណាស់ ប៉ុន្តែក្រែងគេមិនឱ្យទៅព្រោះមាន អស់លោកនៅយាមតាមផ្លូវ មិនឱ្យមនុស្សចំឡែកណាទៅទេ ។

– អស់លោកណា ? ពួកលោកចៅហ្វាយឬ ?



– ...( មីងបររទេះងាកមើលឆ្វេងស្តាំឃើញថាគ្មានមនុស្សនៅជិតទេ ក៏សួរវិញ) អ្នកកំលោះនៅស្រុកណាមិនដែលដឹង ?

– ខ្ញុំនៅជិតទៅដល់ភូមិត្របែក ប៉ុន្តែឪពុកម្តាយខ្ញុំគាត់ជរាទៅ ក៏ ខ្ញុំគិតមករកទទួលទានស្រុកនេះ ក្រែងបានប្រាក់បន្តិចបន្តួចយកទៅចិញ្ចឹម គាត់ ខ្ញុំមិនដែលមកទេ ។

– ដែលមីងថាអស់លោកនោះ គឺពួកចោរណ៎ា គេនាំគ្នានៅឯភ្នំ-ត្បែងឯណោះយូរហើយ ពីដើមមិនសូវមានអំណាចទេ ទើបតែសព្វថ្ងៃនេះ គេចេញមុខពេញទី ហើយគ្មានអ្នកណាទៅជិតទីគេបានទេ ។

– បើអីចឹងឱ្យខ្ញុំធ្វើម៉េចនឹងបានទៅមើលកូនមីងឯង ?

– មិនអីទេ ក្មួយជិះជាមួយរទេះមីងទៅ ចាំទៅដល់ជិតកន្លែងគេ យាមចាំមីងប្រាប់ ហើយក្មួយត្រូវចុះដើរវាងទៅក្នុងព្រៃទៅ ចាំហួសបន្តិច សឹមវិលមករករទេះមីងវិញ ។ គេយាមតែមួយកន្លែងទេ បើទៅដល់កំពង់ ពុទ្រាហើយចាំមីងទៅជំរាបមេគេតែម្តង ត្បិតមេគេនោះមិនសូវប្រកាន់ទេ ព្រោះគេអាងថាពួកយាមខាងមុខបានពិនិត្យមើលមនុស្សសព្វគ្រប់អស់ ហើយ ។

លុះរទេះគោបរដល់ទីកន្លែងហើយ មីង «សុខ» ប្រពន្ធតា-ចាន់ ប្រាប់ទៅ ក៏បុរសអ្នកដំណើរបែកចេញដើរទៅក្នុងព្រៃដូចសំដីគាត់ផ្តាំ ប៉ុន្តែ ដើរទៅជ្រៅបន្តិចទៅ ស្រាប់តែវាឃើញមានមនុស្សប្រុសម្នាក់រត់គេចទៅ ពួនក្នុងគុម្ពោត ។ វានឹកស្មានថាតែពួកចោរយាមល្បាត ក៏រត់យ៉ាងលឿន ចៀសចេញពីទីនោះហើយពួននៅនឹងគុម្ពោតមួយទៀត មិនភ្លេចចោល

ភ្នែកទៅលបមើលបុរសដែលឃើញអម្បាញមិញទេ ។ ឯពោះលបមើល



ទៅ. ឯណោះក៏លបមើលមកដែរ ។ បុរសកំបុតដៃរវល់តែប្រុងខ្លួនពួន អាត្មាខ្លាចមនុស្សចំឡែកនោះឃើញខ្លួនក៏ភ្លេចគិត ឯចោរឃាមល្បាតមែន-ទែនដែលឆែករទេះមីងសុករួចហើយដែលងាកមកឃើញខ្លួនអង្គុយច្បាស់ ថែសគ្មានបាំងនឹងអ្វីសោះ ។ ចោរចូលមកដល់ចាប់សក់ក្បាលខ្លួនទាញឱ្យ



ងើបឈរឡើងដើម្បីមើលមុខ ។ លុះបុរសកំបុតដៃឈរស្រួលបួលព្រម ទាំងមើលស្គាល់ជាក់ជាចោរព្រៃដែលស្លៀកពាក់កាគីគ្មានស្បែកជើងប្រុង ចាប់ខ្លួនយកទៅធ្វើទោស ក៏យារដៃស្ដាំដាល់ថ្គាមអាចោរយ៉ាងខ្លាំង របូត ដៃវាពីសក់ខ្លួន ហើយរត់គេៀសខ្លួនចេញយ៉ាងលឿន ។

ប៉ុន្តែរត់មិនរួចទេអាចោរវាដេញតាមទាន់ ។ ក្នុងពេលនោះមនុស្ស ម្នាក់ទៀត ដែលលបមើលពីក្នុងគុម្ពោតម្ខាងមកនោះឃើញថាបុរសកំបុតដៃ មិនមែនជាពួកចោរទេ ក៏ស្ទុះចេញពីជំរកមកដាល់អាចោរពីក្រោយ ។ អាចោរដែលដកកាំភ្លើងវែងចេញពីស្មាពុំទាន់ក៏បែរមកក្រោយដាល់តបនឹង មនុស្សនេះ ។ សមមាឌធំប៉ុន១គ្នាផង មួយដៃ១ដែលដាល់គ្នានេះបណ្ដាល ឱ្យគូម្ខាង១ ខ្ទាតចោលប្រាណទៅដី សឹងស្លាប់រៀងខ្លួន ។ បានមួយសន្ទុះ អាចោរឃើញសត្រូវវាដួលទៅដីក៏ដកកាំភ្លើងជប៉ុនពីស្មាគិតបាញ់សម្លាប់សត្រូវ វាចោល ទទួលអ្នកកំបុតដៃស្ទុះមកចាប់កាំភ្លើងដណ្ដើមយកចេញ ។ គ្រាប់កាំភ្លើងក៏ផ្ទុះខ្ទាតទៅទីផ្សេងពីទីដែលតម្រង់ទៅ ។ ម្នាក់នោះស្វាង ភ្នែកកាលណា ឃើញបានឱកាសស្រួល ក៏ក្រោកឡើងដាល់ចំមុខអាចោរ មួយដៃយ៉ាងខ្លាំង ។

អាចោរដួលទៅដីសន្លប់ស្ងៀមឈឹង ។ មិនតែប៉ុណ្ណោះវាត្រូវនឹង ស្វាយកាំភ្លើងដែលអ្នកកំបុតដៃដណ្ដើមបាន ហើយវាយថែមលើមុខវា ទៀត វាក៏រិតតែលែងកំរើកខ្លួនសោះតែម្ដង ។

– ខ្ញុំកុំតែបងឯងជួយ កុំអីស្លាប់តែម្ដង (បុរសកំបុតដៃចាប់និយាយ មុន) ខ្ញុំស្មានថាតែបងឯងជាពួកវា បានជាខ្ញុំខំគេចកុំឱ្យបងឯងឃើញ ។

– ងឺ ! ខ្ញុំនេះក៏ដូច្នោះដែរ (មនុស្សម្នាក់ទៀតតប) កុំតែបានប្អូនឯង កុំអីស្លាប់របស់វាទៅដែរ ចុះបងនឯងនៅស្រុកហោមកទីនេះមានការអ្វី ? មិនដឹងជាស្រុកនេះចោរមានឫទ្ធិខ្លាំងទេឬ ? នុ៎ះ ! ពួកវាតាមមកហើយ ។

ក្នុងពេលនោះមានចោរប្រាំនាក់ជិះសេះមក ពីរនាក់នេះឆក់កាំភ្លើងហើយរត់ទៅពួននៅគុម្ពោតមួយយ៉ាងជិត ។ ពួកអ្នកជិះសេះមកដល់វាចែកឱ្យគ្នាវាពីរនាក់ចុះលើកយកអសុភគ្នាវា ។ ឯអាបីនាក់ទៀតជិះសេះតាមរកគូសត្រូវរបស់គ្នាវា ប៉ុន្តែរកពុំឃើញសោះ ក៏យកតែខ្មោចវិលទៅវិញទាំងអស់គ្នាទៅ ។

ខ្ញុំមិនដឹងជាទីនេះមានចោរច្រើនយ៉ាងនេះទេ (បុរសកំបុតដៃក្រោកឡើងលបដើរចេញទៅជើងជាមួយម្នាក់ទៀត) ព្រោះខ្ញុំជាអ្នកស្រុកត្របែកមកលក់អង្ករនៅផ្សាររវៀង ទទួលមីងអីនោះនៅកំពង់ពុទ្រាថាកូនគាត់បាក់ដៃខ្ញុំចង់ទៅសង្គ្រោះកូនគាត់ ព្រោះខ្ញុំចេះមើលបន្ទិចបន្តួចដែររបួសបែបនេះ ចុះបងឯងជាអ្នកស្រុកនេះឬ? ឈ្មោះអីខ្ញុំសុំធ្វើពួកម៉ាក់តែម្តងទៅចុះ ព្រោះខ្ញុំគ្មានទីពឹងអ្នកឯណាទេ ។

– មានអីខ្ញុំអរណាស់ លាក់បាំងអ្វី ដោយខ្ញុំឃើញថាប្អូនឯងជាមនុស្សមិនចូលដៃនឹងចោរ ហើយមានចិត្តប្រហែលជាស្មោះនឹងខ្ញុំៗសុំប្រាប់ប្អូនឯងឱ្យអស់ទៅចុះ ក្រែងលោប្អូនឯងជួយកំលាំងខ្ញុំ ហើយជូនខ្ញុំឱ្យបានដល់គោលបំណងខ្ញុំៗនេះឈ្មោះក្រាញ់ ធ្វើដោយប៉ូលីសសាលាស្រុករវៀងជាន់លោកសុគន្ធា ។ ខ្ញុំសុខចិត្តស្លាប់រស់តែនឹងលោកសុគន្ធា



ចៅហ្វាយខ្ញុំនេះហើយ ឥឡូវខ្ញុំឮដំណឹងថាអាចោរវាយកលោកទៅទុកនៅភ្នំត្បែងទើបខ្ញុំស្កាត់ទៅនេះ ព្រោះលោកជាអាទិទេពនៅស្ថានកណ្តាលនេះជាប្រាកដ ។ លោកកាន់យុត្តិធម៌ល្អណាស់ ។

– ឱ ! បងឯងទៅរកលោកសុគន្ធា ? បើឯចឹងខ្ញុំទៅដែរ បងឯងទៅឯណាខ្ញុំទៅឯណោះដែរ រួចចុះកាំភ្លើងម្តេចមិនយកមកទុកការពារខ្លួន ។

– កាំភ្លើងនេះខ្ញុំមិនប៉ានកាន់ទេ គ្នាគេច្រើនណាស់ បើគេឃើញយើងមានកាំភ្លើង មុខជាគេចាប់យើងបាន យើងមិនងាយតស៊ូនឹងគេឈ្នះទេ ។ មួយទៀតពួកវាបែបជាចេះមន្តគាថាបញ្ចៀសគ្រាប់ផង ។ ខ្ញុំគិតថាធ្វើដូច្នេះស្រួលណ៎ា ! កាលណាយើងបានកាំភ្លើងមួយៗពីដៃចោរយើងលួចយកទៅលាក់ឬកប់ទុកឱ្យចាំកន្លែង លុះពេលក្រោយទៅបើយើងត្រូវការយើងនឹងមករកបានភ្លាម ។ អើមែន ! ប្អូនឯងថាមីងណានៅកំពង់ពុទ្រាដែលប្អូនឯងមកជាមួយរទេះគាត់នោះ ?

– គាត់ប្រាប់ថាប្តីគាត់ឈ្មោះតាចាន់...

– អូ ! មីងសុខឬ ? មីងសុខនេះខ្ញុំមិនដែលស្គាល់ទេ ប៉ុន្តែខ្ញុំឮប្តីគាត់ប្រាប់ថាគាត់ឈ្មោះសុក ។

– អើបងឯងឃើញប្តីគាត់ទេ. គាត់ថាបាត់តាំងពីយប់មិញម្ល៉េះ ។

– ខ្ញុំ ! ថ្ងៃមិនឃើញ ! អាតាចាន់ ! អានេះរួចមកពីអាកញ្ចុះ (ដោយក្រាញ់និទានធ្វើហី) ប្អូនឯងមិនដឹងទេ ខ្ញុំស្មានថាតែអាកញ្ចុះនេះជាមនុស្សល្អជា ស្រាប់តែពីម្សិលមិញនេះខ្ញុំលបតាមមើលអាកញ្ចុះដែល

ដើរលេងជាមួយអាតាចាន់ ។ វាបាននិយាយឱ្យអាតាចាន់ធ្វើឧបាយទិញស្រាឱ្យខ្ញុំផឹក១ស្រវឹងទៅ វានឹងនាំខ្ញុំទៅក្នុងព្រៃដែលមានពួកចោរគ្នាវាចាំបាញ់សម្លាប់ខ្ញុំ ។ នេះប្រហែលជាគេខឹងថាខ្ញុំ មិនចូលចិត្ត ពួកចោរ ...ហើយថាខ្ញុំជាមនុស្សជំនិតរបស់លោកសុគន្ធា ។ ខ្ញុំទើបនឹងដឹងទេពុតអាក្រក់របស់អាញុះនេះ ។ លុះព្រឹកឡើងក៏ឃើញអាចាន់មករកខ្ញុំតាំងពីព្រលឹម ។ ខ្ញុំយល់កិច្ចវាក៏រាប់រកវាជាធម្មតា

ហើយខ្ញុំមិនរឹងទទឹងនឹងសេចក្តីអញ្ជើញរបស់វា ចំពោះខ្ញុំទេ ។ ប៉ុន្តែខ្ញុំប្រយ័ត្នខ្លួនជានិច្ច ។ ស្រាមួយកែវ១ ដែលវាហុចឱ្យខ្ញុំនៅផ្ទះចិន ខ្ញុំគ្មានបានអាស្រ័យបន្តិចទេ ខ្ញុំចាំមើលតែវាងាកទៅណាមួយភ្លែត ខ្ញុំឆ្លៀតចាក់ចោលទៅក្រោយអស់ ។ ខ្ញុំទទួលទានតែបន្តិចក៏ធ្វើជាស្រវឹងទោរនិយាយតែផ្តេសផ្តាសហើយធ្វើជាទទ្រេតទទ្រោត រួចវាសុំឱ្យខ្ញុំជូនវាទៅរកកូនវា ថាកូនវាវង្វេងបាត់ក្នុងព្រៃ វាភូតខ្ញុំដោយស្មានថាខ្ញុំស្រវឹងស្រាមែនទែន ។ ខ្ញុំក៏សុខចិត្តទៅតាមវា ។ លុះដើរចេញពីផ្សារបន្តិច ទៅឆ្ងាយពីប្រជុំជន ប៉ុន្តែពុំទាន់ដល់ព្រៃធំទេ ខ្ញុំធ្វើជាទៅបត់ជើងតូចនៅគុម្ពោតឈើ ប៉ុន្តែគឺក្នុងគុម្ពោតឈើនេះហើយ ដែលខ្ញុំបានក្រោកតាំងពីយប់យកកាំភ្លើងមកលាក់ទុក ដើម្បីការពារខ្លួនខ្ញុំ១ ក៏ដកយកកាំភ្លើងនោះ មកចងរលវាដែលគ្មានកាំភ្លើងនៅដៃទេ ។ ខ្ញុំក៏កំហែងឱ្យវាដោះសំលៀកបំពាក់វាចេញហើយ ឱ្យទទួលស្លៀកពាក់នូវខោអាវ ឯកសណ្ឋានរបស់ខ្ញុំដែលខ្ញុំដោះឱ្យវា រួចខ្ញុំស្លៀករបស់វាវិញខ្ញុំបង្ខំឱ្យវាដើរមុខខ្ញុំជាដរាប ។ លុះទៅដល់ក្នុងព្រៃ ពួកចោរឃើញ អាតាចាន់ ស្មានថាតែរូបខ្ញុំ



ក៏បាញ់វាស្លាប់ទៅ ចំណែកខ្ញុំរត់គេចខ្លួនទៅម្ខាងឆ្ងាយទៅ១ ពុំឃើញពួកចោរដេញតាមខ្ញុំសោះ ។ ខ្ញុំធ្វើយ៉ាងនេះទើបសុខខ្លួន ។ បើ សិនជាខ្ញុំបាញ់តាចាន់សម្លាប់ដោយដៃខ្ញុំប្រហែលជាអាកញុះ ឬពួកចោរ តាមសម្លាប់ខ្ញុំសងសឹកគ្នាវាជាមិនខាន ឬមួយជាប់គុកដោយសារលោក វង្សរិទ្ធិកូនអាកញុះផងក៏មិនដឹង ។

– ដូច្នេះហើយតើ ! បានជាពីម្សិលមិញខ្ញុំមកអង្កេត ក៏លោកចៅហ្វាយស្រុកវង្សរិទ្ធិប្រាប់ខ្ញុំថា មានថ្លែងការណ៍ពីចៅហ្វាយស្រុកសណ្តាន់ថាថីដោយឯងស្លាប់គេរើសបានអសុភនៅជិតស្រុកនោះ ខ្ញុំក៏ស្មានច្បាស់ថាថីឯងស្លាប់បាត់ទៅហើយ១ នឹកស្តាយថាខ្ញុំខាតសាក្សី សំខាន់ម្នាក់ទៅហើយនឹងស៊ើបតទៅទៀតពុំបានការពេញលេញទេ ។

– ប្អូនឯងនិយាយយ៉ាងម្តេចខ្ញុំមិនយល់សោះ ប្អូនឯងថាមកស៊ើបអង្កេតពីម្សិលមិញ...

– ហា ! ហា ! ខ្ញុំប្រាប់ថីដោយឯងឱ្យច្បាស់ទៅចុះព្រោះយើងមានគោលបំណងដូចគ្នា ហើយយើងទៅជាមិត្តសម្លាញ់គ្នាជិតដិតផង ខ្ញុំនេះឈ្មោះសាវ័ណ្ស មានឋានៈជាអធិការប៉ូលិសជាតិធ្វើការនៅភ្នំពេញមានបេសកកម្មមកស៊ើបការពីរឿងលោកសុគន្ធា ព្រមទាំងមករកដានលោកឱ្យឃើញដើម្បីតិតដណ្តើមលោកពីដៃចោរមកវិញដោយតិរៈខ្ញុំ១នឹងមកជាផ្លូវការទៅឃើញថាមិនងាយបានការទេហេតុនេះហើយបានជាពីម្សិលមិញ កាលដែលខ្ញុំត្រឡប់ពីសាលាស្រុករវៀងទៅវិញដល់ត្រង់ថ្នល់បែក ខ្ញុំក៏បានចូលទៅស្នាក់នៅផ្ទះអ្នកស្រុកជិតនោះ ។ ខ្ញុំសុំទិញសំលៀក

បំពាក់គេដែលប្រើធម្មតាព្រមទាំងទិញអង្ករនឹងសង្រែកគេរែកអង្ករមករវៀងវិញ ទើបបានជួបនឹងមីងសុកនេះ ។

– ឱ ! សូមទោនព្រះតេជគុណ ខ្ញុំបាទមិនស្គាល់ហើយបានជានឹកស្មានខុសទៅហើយ ។

– ទេមិនអ្វីទេថីដោយ ! ខ្ញុំមិនចេះប្រកាន់ដូចគេទេ បើថីដោយឯងអាណិតខ្ញុំ កុំហៅខ្ញុំព្រះតេជគុណធ្វើអី មួយទៀតក្នុងព្រៃដូច្នេះ យើងត្រូវលាក់អត្តសញ្ញាណប័ត្រយើងកុំឱ្យគេស្គាល់ក្រែងមានគ្រោះថ្នាក់ ត្រូវហៅប្អូន១ដដែលចុះព្រោះខ្ញុំក្មេងជាង ។

– បើដូច្នោះសុំកុំហៅខ្ញុំបាទថីដោយ១....

– មែនហើយ ខ្ញុំច្រឡំទេ ។

– អុះ ! គេថាខ្ញុំស្លាប់ ? ហើយគេរើសបានខ្មោចខ្ញុំនៅជិតស្រុកសណ្ដាន់ អុះស្រុកកំពង់ត្របែកនោះឬ ? បើឯចុះមានតែអាចោរដែលបាញ់នេះវាពុំស្គាល់ខ្ញុំពិតហើយ វាឃើញតែស្បៀកពាក់កាគីក៏វាថាខ្ញុំទៅ ប៉ុន្តែខ្ញុំឆ្ងល់ណាស់មុខអាគាចាន់គ្មានដូចខ្ញុំសោះហេតុម្ដេចក៏គេថាខ្ញុំ! គេមិនពិនិត្យរូបថតខ្ញុំ ដែលបិតជាប់នឹងកាតដាក់ក្នុងហោប៉ៅទេឬ ?

– ទេធ្វើម៉េចនឹងគេអាចផ្ទឹមបាន ? ចុះបើអសុភនោះមានតែខ្លួនទទេបាត់ក្បាលមិនដឹងទៅណា ។

– បើបាត់ក្បាលមានតែអាចោរបានកាត់ក្បាលអាចាន់ទៅហើយ ។

– យីអាកញ្ចុះវាក៏អាក្រក់ខ្លាំងម្ល៉េះ ? ធ្វើការរាជការផងចូលដៃនឹងចោរផង ។



– ត្រង់ចូលដៃនឹងចោរនោះ ខ្ញុំទើបនឹងដឹងនេះទេ ប៉ុន្តែថាវាធ្វើការរាជការនោះមានធ្វើអ្វីវា ?

– ក្រែងធ្វើដោយប៉ូលីសដូចបងឯងឬ ?

– ទេ ! អានេះមានដីកាឯណាតាំងវាឱ្យធ្វើភ្នាក់ងារប៉ូលិស ? វាជាមនុស្សសាមញ្ញមិនដឹងមកពីណា អុះ ! ពីដើមវានៅកំពង់ធំហើយរកការធ្វើគ្មាន ក៏មកសុំនៅនឹងលោកចៅហ្វាយដែលឈរនៅស្រុករវៀងនេះមុនលោកសុគន្ធាទៅទៀត ។ ប៉ុន្តែអានេះប៉ិនប្រសប់ណាស់ខាងឯបអបនិយាយបញ្ចុះបញ្ចូលនាយចៅហ្វាយ ចេះយកគាប់គ្មានអ្នក ណាផ្ទឹមបាននឹងវាទេ ។ លោកចៅហ្វាយដោយត្រូវចិត្តនឹងវាខ្លាំង ក៏បាន ធ្វើសំបុត្រទៅសុំរាជការឱ្យតែងតាំងវាឱ្យធ្វើជាភ្នាក់ងារប៉ូលីសស្រុក ។ ប៉ុន្តែសុំប៉ុន្មានដងហើយគេគ្មានឱ្យតាមសុំសោះ រហូតទើសឥឡូវនេះ គេថាក្នុងបញ្ជីថ្កោលទោសមានឈ្មោះវាជាប់គុកច្រើនដងណាស់ តែងតាំង តាមសុំពុំបានទេ ។ លោកចៅហ្វាយមុននោះមិនរវល់នឹងការតែងតាំងទេ ដោយហេតុទុកចិត្តក៏ប្រគល់ការឱ្យធ្វើសព្វគ្រប់ដូចជាភ្នាក់ងារប៉ូលីស មែនទែនទៅ ។ មិនត្រឹមតែធ្វើជាកូនប៉ូលីសធម្មតា វាមានលើកខ្លួនវា ជាដោយត្រួតត្រាលើភ្នាក់ងារឯទៀត ។ ភ្នាក់ងារទាំងឡាយមានអ្នកណា ហ៊ានហើបមាត់ ? ព្រោះខ្លាចលោកចៅហ្វាយស្រុកដែលស្រឡាញ់វា ជាងកូនបង្កើតផង ។ លុះលោកចៅហ្វាយសុគន្ធាផ្លាស់មក វាទាក់លោក នេះឱ្យស្លាប់ចិត្តដោយសារវាទៀតនេះដូចពាក្យចាស់គេថា «ប្រាជ្ញាមិន ស្មើប្របអាបាក់ស្លឹកត្រចៀកខ្លបមិនស្មើអាឡើមឡឹម» ។ ហេតុតែលោក សុគន្ធាត្រូវចិត្តនឹងវាពេកទៅ

លោកមិនរវល់នឹងផ្ទៀងមើល តើវាជាអ្នក រាជការត្រឹមត្រូវមែនឬយ៉ាង ណាទេបើគិតមែនទែនទៅគ្រោះថ្នាក់របស់ លោកដែលរងសព្វថ្ងៃនេះ គឺជាលទ្ធផលនៃការធ្វេសប្រហែសរបស់លោក បន្តិចហើយ....

– មើលឈប់សិន !

អ្នកទាំងពីរកំពុងនិយាយគ្នាក្នុងដំណើរ ស្រាប់តែមកដល់ភូមិកំពង់ពុទ្រាពុំដឹងខ្លួន គេមើលឃើញដំបូលផ្ទះស្លឹកដែលសង់លើសសរខ្ពស់ៗ លេចចេញពីកំពូលព្រឹក្សាទាបៗហើយជ្រកក្រោមម្លប់ដើមឈើទាលធំៗ ដ៏មានស្លឹកញឹកដូចសំពត់តម្បាញ ។ រទេះមីងសុកទើបតែនឹងបត់ចូលទៅក្នុងច្រករបងផ្ទះគាត់ ។

– នោះហ្ន៎ ! នៅមាត់ថ្នល់ឯនាយ មានគេយាមពីរបីនាក់ដែរ (ដោយក្រាញ់ចង្អុលប្រាប់) យើងដើរស្រូតឱ្យបានឆាប់ចូលទៅក្នុងផ្ទះមីងសុខ ទាន់មុនវាឃើញយើងនេះ យើងដើរមកផ្លូវកាត់ហើយបានជាវាមិនដឹងនោះ ។

– យី ខ្ញុំបារម្ភនឹងបងឯងណាស់ (លោកសាវ័ណ្យពោល) ខ្លាចក្រែងមីងសុកគាត់ស្គាល់បងឯង ព្រោះបងឯងជាសត្រូវនឹងប្ដីគាត់ស្រាប់ផង ក្រែងមិនស្រួល....

– មិនអីទេ គាត់មិនដែលស្គាល់ខ្ញុំទេ មួយទៀត បើសិនជាមានអ្នកណាធ្លាប់ស្គាល់ខ្ញុំពីថ្ងៃមុននោះ គេក៏អាចស្គាល់ខ្ញុំក្នុងពេលនេះបានដែរ ព្រោះខ្ញុំដំណែងខ្លួន គឺដាក់ពុកមាត់ហើយលាបធ្យូងមុខឱ្យខ្មៅកាត់សក់ជ្រុងនេះ មួយទៀតទៅភ័យអ្វីខ្ញុំនឹងលាក់បំពួនមុខខ្លះទៅ ប៉ុន្តែបើធ្វើយ៉ាងនេះហើយគេនៅតែស្គាល់ទៀត យើងមិនចេះតស៊ូឬ ? គេថាលិចសិមលោតដល់តម្កោតសិមតោង ។

លោកសាវ័ណ្យ នឹងថីដោយក្រាញ់ មានមធ្យោបាយយ៉ាងណោតទៅ

ជំរុំនៃកងចោរមានឬទេ សូមរង់ចាំអានតទៅ

ខ្សែទីពីរដែលមានចេញក្នុងពេលឆាប់ៗនេះ ។

## ជំពូក៩

## ជំរុំចោរព្រៃ

បួនទិវារាត្រីហើយ មនុស្សទាំងឡាយក្នុងព្រះរាជធានីក្តី ក្នុងខេ
ក្រៅក្តី ដែលបានធ្លាប់ស្គាល់ធ្លាប់ឮឈ្មោះឬបានស្រង់ក្លិនក្រអូបអំពីគុ
សម្បត្តិនៃលោកសុគន្ធា នឹងគ្រួសារលោកមករឿយៗនោះ នឹកឆ្ងល់ក្នុងចិ
តែរៀងខ្លួនថា «ទេវតាម្តេចក៏លោកមិនអាណិតអាសូរដល់មនុស្សល្អសោះ
ម្តេចក៏លោកបំផ្លាញតែមនុស្សល្អយ៉ាងនេះ? បំផ្លាញអស់មួយពូជមួយអម្
គ្មានម្នាក់ណាក្នុងគ្រួសារគ្រាន់នឹងបណ្តុះកេរ្តិ៍ឈ្មោះឱ្យបានវែងឆ្ងាយទៅទៀត
សោះ បើធ្វើតែយ៉ាងនេះទៅជោគវាសនារបស់ប្រទេសនឹងទៅជាយ៉
ណាទៅអេះ ?

មិនមែនទេ ! លោកសុគន្ធាមិនទាន់ស្លាប់ទេ ប៉ុន្តែបើស្លាប់ទេ
ល្អជាងនៅរស់ ។ កាលដែលចោរវាលុកលុយបាញ់ប្រយុទ្ធនឹងលោក
ថ្ងៃច័ន្ទនៅគេហដ្ឋានលោកនោះ នៅពេលដែលលោកទាល់ច្រក ហើយ
លោតតាមបង្អួចទៅក្រោមមានគ្រាប់របស់ចោរមួយគ្រាប់ មកទំលុះគ
ដៃខាងឆ្វេងហើយអាចោរព្រួតគ្នាមកកន្ត្រប់ចាប់លោក ព្រមទាំងវាយគ
លោកជាដំណំលុះត្រាតែលោកសន្លប់បាត់ស្មារតី ។ អាចោរស្មានថាជី
ជីវិតលោកក្ស័យទៅហើយ បានជាវានាំគ្នាសែងលោកយកទៅជំរុំវាដោយ
ត្រែស្ទែង ថានឹងយកទៅធ្វើបុណ្យឱ្យលោក ឱ្យបានសមសក្តិនោះ



វាធ្វើបែបនេះមិនមែនជាការចំឡែកទេ ។ ពីមុនៗមកវាធ្លាប់ដើរផ្លូវនេះ ហើយបើមេវាមិនចូលចិត្តនឹងមនុស្សណាហើយ វាប្រើកូនចោរទៅចាប់ ឬបាញ់សម្លាប់ដឹកនាំរូបសត្រូវនោះមកឱ្យវា ។ បើជននោះស្លាប់ វានឹងធ្វើពិធីមួយបែបតាមអំពើចិត្តវា ជាកិច្ចគួរតិះដៀលមិនគួរបើនឹងយកមកពណ៌នាទេ ។ តែបើសិនជាជននោះនៅរស់វិញ វានឹងធ្វើទារុណកម្មឱ្យអស់ចិត្តកំណាចរបស់វា ។

កាលនោះ ពួកចោរបានបណ្តើរនាងគន្ធពិដោរ ដែលរើបំរះពីកណ្តាប់ដៃពួកវា ដោយគ្មានបានប្រយោជន៍អ្វី ។ ប៉ុន្តែទោះបីវាចាប់ដៃ



នាងម្នាងម្នាក់ជាប់យ៉ាងណាក៏ដោយ គ្មានអ្នកណាហ៊ានវាយដំនាង
ប៉ះពាល់ដល់រូបកាយនាងទេ ព្រោះដោយកញ្ចុះដែលពួកចោរគោរព
នឹងមេវានោះ ដើរមើលការខុសត្រូវពីក្រោយ ។ ពេលនោះកុំតែងងឹត
បើសិនជាគេមានចង្កៀងអ្វីយកមកបញ្ចាំងមើលមុខមនុស្សម្នាក់នោះ
ប្រហែលជាគេនឹងឃើញមុខមាត់ញញឹមយ៉ាងស្រស់ខុសពីធម្មតា ។ ក្បួ
ចោរកំណាចនេះ ចេញពីផ្សារវៀងទៅ វាបត់ទៅឧត្តរទិស កាត់ព្រៃ
សំដៅទៅមាត់ក្រាលថ្ម ដែលតម្រង់ឆ្ពោះទៅប៉ុស្តិ៍ជាំខ្សាន ។ ប៉ុន្តែទេ
ដល់ត្រង់ភ្នំត្បែង ក៏វាបែកទៅខាងស្ដាំចូលតាមផ្លូវលំមួយដែលកាត់ព្រៃ
គឺនៅក្នុងព្រៃភ្នំនេះហើយ ដែលពួកវាសង់ជំរុំដើម្បីប្រកបនូវអាជីវក
ដោយសន្តិភាពតាំងពីដើមរៀងមក ។ ក្នុងព្រៃនេះដើមឈើធំៗដុះញ
ណាស់ ។ មែកដើមមួយរុញចូលទៅលាយនឹងមែកដើមមួយទៀត ល
ត្រាតែស្លឹកប៉ះហើយតម្រួតគ្នាយ៉ាងក្រាស់ជិតស្លុង មិនឱ្យគេមើលពីក្រោយ
ទៅឃើញមេឃមួយចំរៀកណាឡើយ ។ មានតែនៅដោយផ្លូវលំនេះទ
ដែលទឹកសន្សើមអាចជ្រួតជ្រាបមកលាងសំអាត ស្លឹករុក្ខជាតិតូចៗអំ
លំអងធូលីបាន ។ គឺដោយសារបានទទួលនូវសន្សើមពេលអធ្រាត្រក្នុ
ព្រៃនេះហើយ ដែលលោកសុគន្ធាបានកន្លងចេញផុតពីទ្វារមរណៈ
លោកដឹងខ្លួនឡើងក៏បានដឹងថាលោកនៅក្នុងកណ្ដាប់ដៃចោរហើយ ស
លោកអស់កំលាំងខ្លាំងណាស់ផង នឹងរកមធ្យោបាយយ៉ាងណាដើម្បីដោ
ខ្លួន ឱ្យបានរួចផុតពីការវិនាសពុំបាន លោកក៏តាំងចិត្តនៅស្ងៀមកុំឱ្យវាដឹ
បណ្ដោយឱ្យវាសែងលោកឱ្យបានដល់ទីវាទៅចុះ ។ ប៉ុន្តែបំណងនេ



ទៅជាឥតប្រយោជន៍ទៅវិញ ដោយរបួសដៃដែលបង្ហូរឈាមពេកនោះ បណ្ដាលឱ្យលោកស្រេកទឹកជាខ្លាំង ។ លោកអត់ទ្រាំពុំបាន ក៏ភ្ញាក់ខ្លួនឡើងស្រែកសុំវា ។

– អូ ! វាមិនមែនងាប់ទេ (នាយតម្រួតចោរម្នាក់ស្រែកឡើង) នេះរិតតែស្រួលហើយ ព្រោះបានធូកំលាំងពួកយើងកុំឱ្យហត់នឿយនឹងសែងវា ។

– អូយ ! សុំទឹក... (លោកសុគន្ធាទន្ទេញដដែលៗ) អូយ ! សុំទឹកខ្ញុំស្រេកទឹកណាស់ ! ដាច់ខ្យល់ឥឡូវហើយ ។

– គ្មានអាណាមានទឹកឱ្យវាទេ (នាយកញ្ចុះបន្ថែម) យកខ្សែចងស្លាបសេកដៃវា ហើយឱ្យវាដើរទៅ ។

– អូយ ! សុំលោករកសំពត់រុំដៃឱ្យខ្ញុំផងឈឺណាស់...

ក្នុងពេលដែលពួកកូនចោរដាក់គ្រែស្នែងនៃលោកសុគន្ធាចុះទៅដី នាងគន្ធពិដោរឃើញ ឪពុកមានជីវិតឡើងវិញ នាងហក់ទៅឱបឪពុក ប៉ុន្តែមិនបានប៉ុន្មានទេ នាងត្រូវគេទាញបណ្ដេញចេញគ្មានប្រណី ហើយរុញច្រានឱ្យដើរទៅមុខទៀតតាមបញ្ជាការរបស់នាយកញ្ចុះកំណាច ។ ម៉្លោះហើយនៅក្នុងព្រៃស្ងាត់នេះ មានតែសូរទំនួញរបស់នាងទេដែលលៀកចេញពីសូរមាត់កោកកាកអ៊ូអររបស់ពួកចោរ ដើម្បីរសាត់ទៅឆ្ងាយតាមខ្យល់ជំនោរ ។ សូរទំនួញនេះ មកចាក់ដោតទ្រូងលោកសុគន្ធាឱ្យខ្លោចផ្សានឹងកូនស្រីសម្លាញ់របស់លោកណាស់ ។ លោកមានកម្លាំងឯណានឹងទ្រ ខ្លួនខំដើរតាមអំណាចពួកជនទុរាចារ លោកឈានបានតែមួយជំហានពីរ

ក៏ទន់ទ្រោមផ្តួលប្រាណទៅដីដូចជាស្លាប់ខ្លួនទាំងមូល ។ លោកនៅ
តែមាត់ដែលបញ្ចេញសំឡេងខ្សាវៗថា «កូន !...កូន....» ។ ចោរ



ល្បងឱ្យលោកក្រោកឈរឡើងដើរម្តងជាពីរដង ប៉ុន្តែកម្លាំងលោកអតី
ចៅហ្វាយស្រុកកាន់តែថយទៅៗ ។ សភាពនេះធ្វើឱ្យឃីតយូរដំណើរពួ
វាណាស់ ។ ប៉ុន្តែវាគ្មានធុញទ្រាន់ឬប្រញាប់ទៅណាទេ ។ វាទុករូ



លោកនេះ ដូចជាល្បែងរបស់វាគ្រាន់នឹងលេងកែអផ្សុក ។ ខ្លះជេរខ្លះស្តី ខ្លះទះខ្លះតប់ លុះត្រាតែភ្លឺហើយឃើញថារូបល្បែងរបស់វាជិតបាត់ដង្ហើមទៅវិញ ទើបវាលើកលោកបោះទៅលើគ្រែស្នែងបន្តដំណើរទៅជំរុំវា ។

ជំរុំពួកចិត្តអាក្រក់ទាំងនេះ នៅទីងជើងភ្នំតៀង កណ្តាលព្រឹក្សាយ៉ាងខ្ពស់ ។ គេពុំអាចដឹងថាពួកចោរសង់ជំរុំនេះចំនួនប៉ុន្មានឆ្នាំមកហើយទេ ព្រោះមាំធំសម្បើមណាស់ ។ គេតែងច្រឡំថាជាប្រាសាទបូរាណមួយដែរ ។ គេហដ្ឋានទាំងឡាយ ធ្វើសុទ្ធតែអំពីថ្មប្រក់ក្បឿង ហើយតាំងទីកន្លែងសមរម្យតាមផែនទីដែលគូរដោយដៃអ្នកជំនាញ ។ នៅចំកណ្តាលមានសាលមួយយ៉ាងធំ បង្ហាញរូបដូចជាព្រះវិហារក្នុងបច្ចុប្បន្នកាលបន្តិច ដូចជាប្រាសាទបូរាណប្រទេសអេស៊ីបបន្តិច ។ សាលនេះសំរាប់មេវាចាត់ការសព្វសារពើរាល់ព្រឹករាល់ល្ងាច មេចោរអង្គុយឱ្យគេគោរព ។ មិនថាតែពួកកូនចោរទេ សូម្បីតែអ្នកស្រុកដែល មានផ្ទះជិតឆ្ងាយក្នុងភូមិភាគជើងភ្នំនោះ ក៏ទុកមេចោរធំនេះដូចជាព្រះអាទិទេព របស់គេដែរ ហើយនាំគ្នាមកធ្វើវត្តប្រតិបត្តិមិនហ៊ានខានពេល ណាឡើយ ។ ពួកកូនបង្គាប់ដែលពាក់សក្តិយសដូចទាហានដែរនោះ មានទីដំណេកនៅផ្ទះមួយម្នាក់ដែលសង់ប្របទាំងពីរខាងនៃសាលកណ្តាល ។ ពួកកូនទាហានមានរោងមួយវែងដែលធ្វើពីក្រោយ ទុកឱ្យនៅចំរុះគ្នាតែម្តង ។ មានរោងមួយទៀតធំហើយមាំនៅពីក្រោយគេបំផុត សំរាប់ធ្វើជាគុកដាក់ពួកឈ្លើយដែលចាប់បានមក ។ កាំភ្លើងនឹងគ្រាប់រំសេវគេទុក ក្នុងឃ្លាំងដែលគេសង់មួយដាច់តែឯងយ៉ាងមាំ ។ ឯមាសពេជ្រដែលវា ដណ្តើមពីគេបានមកនេះ